# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ០៩៩ ក.ក.ប.វ/ប្រក.

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០០៦

## ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
- បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញប្រកាសលេខ ១០៣ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញប្រកាសលេខ ២៦៥ សកបយ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញប្រកាសលេខ ៥១៣ សកបយ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
- បានឃើញលិខិត ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៦ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល



អាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៨៨ ៤៣ ៧៥ ទូរសារ : (៨៥៥-២៣) ៨៨ ៤៣ ៧៦

- បានឃើញលិខិត ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៦ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សំរេច

**ប្រការ១:** - តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោមនេះ

### I- *សមាជិកដែលស្នើឡើងដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ*

១- លោក អាំង អេងថុង

២- លោក គីម-ឃាត ដារ៉ារិទ្ធ

៣- លោក គង់ ផល្លៈ

៤- លោក កុយ នាម

៥- លោក ម៉ែន និម្មិត

៦- លោក ញាន សុមុន្និន្ទ

៧- លោក ប៉ែន ប៊ុនឈា

៨- លោក រុន សារ៉ាយ

៩- លោក សុខ ម៉ាធឿង

១០- លោក តាំង ទ្រី

### II- *សមាជិកដែលស្នើឡើងដោយសមាគមនិយោជក*

១- លោកស្រី ឈីវ ភិរម្យ

២- លោក ហែម ហួណារិទ្ធ

៣- លោក អ៊ឹង សុទ្ធី

៤- លោក កៅ ថាច

៥- លោក គល់ វឌ្ឍនា

៦- លោក លី តៃសេង

៧- លោក ម៉ារ សំបូរណា

៨- លោក អ៊ុក រី

៩- លោកស្រី សេង វូចហ៊ុន

១០- កញ្ញា យូ សួនទី

III- សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត (សហព័ន្ធសហជីព)

១- កញ្ញា អាន វីរៈ

២- លោក អន ណន

៣- លោក ហួន ជុនឌី

៤- លោក លីវ សុវណ្ណា

៥- លោក សុង វណ្ណស៊ីន

៦- លោកស្រី ស៊ីន គីមស៊ាន

៧- លោក សួង សុផល

៨- លោក ទូន ស៊ីផាន់

៩- លោក វង្ស វណ្ណា

១០- លោក វ៉ៃន ពៅ

**ប្រការ២:** ~ យោងតាមមាត្រា៣១២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភារកិច្ចដូចតទៅ :

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃក្រៅពីបញ្ហា ដែលមានបញ្ជាក់ក្នុងកំណត់ហេតុ មិនព្រមសះជា ឬ បញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះ ដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនិងការបកស្រាយ និងការអនុវត្តន៍បញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះ ដោះស្រាយដោយសមធម៌ ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ច នៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ច នៃកម្មករ និយោជិត ដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះ មានអំណាចអង្កេតគ្រប់បែបយ៉ាង នៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលមានប្រយោជន៍ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះ អាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវលាក់អាថិកំបាំងវិជ្ជាជីវៈ ចំពោះពត៌មាន និងឯកសារទាំងឡាយ ដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹង ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣:** ~ កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទបញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃ ទី ២១ ខែ មេសា ឆ្នាំ ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង ។

**ប្រការ៤:** ~ សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦។

**ប្រការ៥:** ~ ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ញៀប ប៊ុនជិន

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួង
ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់សមាគមនិយោជក "ដើម្បីជ្រាប"
-គ្រប់សហព័ន្ធសហជីព "ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ